# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:...០២...សរ.ណ.ន**

## សារាចរណែនាំ

## ស្តីពីការចាត់បញ្ជូនប្រធានមន្ទីរអង្គភាពជំនាញនានា ជុំវិញខេត្ត-ក្រុង ទៅចូលរួមសិក្សារយៈពេលវែងនៅក្នុងប្រទេស និងក្រៅប្រទេស

ផ្អែកតាមមាត្រា ២២ នៃច្បាប់ស្ដីពីលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និងមាត្រា៤ នៃច្បាប់ ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ របស់ខេត្ត-ក្រុង និងផ្អែកតាមខ្លឹមសារនៃសារាចរណែនាំ លេខ ១០ សរ.ណន ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាលបានកំណត់ថា អភិបាលខេត្ត-ក្រុង ជាតំណាងរបស់រដ្ឋបាលកណ្តាលនៅក្នុងមណ្ឌលដែនដីរបស់ខ្លួន មានភារកិច្ចក្នុងការសំរុះសំរួលតម្រង់ទិសដៅ ជំរុញតាមដានការអនុវត្តន៍ និងមានភារកិច្ចជាអ្នកផ្តល់យោបល់ទៅលើកិរិយាមារយាទ ការគោរពវិន័យ សាមត្ថិភាពរបស់ប្រធានមន្ទីរ អង្គភាពនានា និងជាអ្នកចូលរួមពិគ្រោះយោបល់ជាមួយក្រសួង-ស្ថាប័ននានា លើបេក្ខជនដែលត្រូវតែងតាំងជាប្រធានមន្ទីរអង្គភាពជំនាញនានានៅខេត្ត-ក្រុង ។

កន្លងមករាជរដ្ឋាភិបាលបានសង្កេតឃើញថា រាល់ការតែងតាំងប្រធានមន្ទីរអង្គភាពនានា នៅតាមខេត្តក្រុង សុទ្ធតែត្រូវបានពិគ្រោះយោបល់ និងមានការឯកភាពគ្នារវាងក្រសួង-ស្ថាប័នសាមី និងអភិបាលខេត្ត-ក្រុងសាមីទាំងអស់ ។ ដោយឡែក ចំពោះការចាត់បញ្ជូនប្រធានមន្ទីរអង្គភាពជំនាញនានាក្រោមឱវាទទៅចូលរួមសិក្សារយៈពេលវែងនៅក្នុង និងក្រៅប្រទេស ក្នុងរយៈពេលកន្លងមក ក្រសួង-ស្ថាប័នសាមីខ្លះ ពុំបានធ្វើការពិគ្រោះយោបល់ និងមានការឯកភាពពីអភិបាលខេត្ត - ក្រុងសាមីនិមួយៗ ជាមុនទេ ។

ដោយមើលឃើញពីការលំបាករបស់អភិបាលខេត្ត-ក្រុងនិមួយៗ ក្នុងការគ្រប់គ្រងដែនដី នៃខេត្ត-ក្រុងរបស់ខ្លួន និងដើម្បីធានាអោយបាននូវយន្តការគ្រប់គ្រងរដ្ឋបាល និងនយោបាយទូទៅក្នុងដែនដីអោយដំណើរការមានប្រក្រតីភាព និងមានប្រសិទ្ធភាពខ្ពស់ រាជរដ្ឋាភិបាលដាក់បទបញ្ជាអោយក្រសួង-ស្ថាប័ននិមួយៗមុននឹងធ្វើការចាត់បញ្ជូនប្រធានមន្ទីរអង្គភាពជំនាញនានានៅតាមខេត្ត-ក្រុង ទៅចូលរួមសិក្សារយៈពេលវែងនៅក្នុង និងក្រៅប្រទេស ចាំបាច់ត្រូវមានការពិគ្រោះយោបល់អោយបានឯកភាពពីអភិបាលខេត្ត-ក្រុងសាមីនិមួយៗ ជាមុនសិន ។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង-ស្ថាប័ន និងខេត្ត-ក្រុង ត្រូវខិតខំអនុវត្ត អោយទទួលបានលទ្ធផលល្អ ដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០២*

**នាយករដ្ឋមន្ត្រី**

ចំលងជូន :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់សាលាខេត្ត-ក្រុង
- [illegible]